# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## ស្តីពី
## កិច្ចជួបពិភាក្សាការងារ ឯកឧត្តម អៀង មូលី ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយទីប្រឹក្សាបច្ចេកទេស French 5% FEI



កាលពីវេលាម៉ោង១៥:៣០ ថ្ងៃទី២១ ខែ តុលា ឆ្នាំ២០១៥ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអនុញ្ញាតឲ្យលោក **Sam Plummer** នាយកគ្រប់គ្រងធនធានមនុស្ស នៃ Institutional and Organizational Capacity Development និងលោក **Pak Kimchoeun** អ្នកស្រាវជ្រាវ ដែលជាទីប្រឹក្សាបច្ចេកទេសរបស់ French 5% FEI ចូលជួបដើម្បីរាយការណ៍ និងបង្ហាញអំពីរបាយការណ៍បឋម ដែលលោកទាំងពីរបានធ្វើការសិក្សា និង ស្រាវជ្រាវ ។

ផ្អែកតាមកិច្ចសន្យាដែលបានធ្វើជាមួយCCC/GFATM លោកបានបំពេញការងារសិក្សាស្រាវជ្រាវអំពីការគ្រប់គ្រងធនធានមនុស្សរបស់ការិយាល័យទទួលជំនួយផ្ទាល់ពីមូលនិធិសកល នៃក្រសួងសុខាភិបាល ដោយបានធ្វើការទំនាក់ទំនង និងសិក្សាជាមួយតំណាងក្រសួងសុខាភិបាល( ប្រធាន

នាយកដ្ឋានបុគ្គលិក អគ្គនាយកបច្ចេកទេស អគ្គនាយកដ្ឋបាលនិងហិរញ្ញវត្ថុ) តំណាងក្រសួងមុខងារសាធារណៈ ព្រមទាំងតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ជាលទ្ធផល លោកទីប្រឹក្សាបានរៀបចំជារបាយការណ៍បឋមដែលបង្ហាញពីផែនការនៃការផ្ទេរការគ្រប់គ្រងធនធានមនុស្សដែលផ្តល់មូលនិធិដោយមូលនិធិសកល(GFATM HR Funding Transition Plan)ដោយលើកឡើងពីជម្រើសផ្សេងៗរួមទាំង គុណសម្បត្តិ គុណវិបត្តិ នៃជម្រើសនិមួយៗរួមទាំងដំណោះស្រាយក្នុងគោលបំណងរក្សានូវចីរភាព សុខដុមនីយកម្ម និងការគាំទ្រដល់ការអនុវត្តគម្រោងកម្មវិធីមូលនិធិសកលក្រោយឆ្នាំ២០១៧ ដោយបានរៀបចំជាslidesសម្រាប់ធ្វើបទបង្ហាញ ក្នុងគោលបំណងសុំការគាំទ្រ និងយល់ព្រមពី **ឯកឧត្តមទេសរដ្ឋមន្ត្រី**។

ក្រោយការពិនិត្យ និងស្តាប់ការបកស្រាយរបស់ជំនួយការបច្ចេកទេសដោយមានការសួរបញ្ជាក់យ៉ាងយកចិត្តដាក់រួចមក **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានប្រសាសន៍៖

- ឯកភាពចំពោះរបាយការណ៍បឋមនេះ
- សុំឲ្យទីប្រឹក្សាបច្ចេកទេស ត្រឡប់ទៅជួបជាមួយមន្ត្រីជំនាញរបស់ក្រសួងសុខាភិបាលម្តងទៀតដើម្បីត្រៀមរៀបចំឯកសារតាមសំណើរបស់មូលនិធិសកលឲ្យបានមុនបំណាច់ឆ្នាំ២០១៥ និងបញ្ជាក់ពីរបាយការណ៍បឋមនេះ មុននឹងធ្វើបទបង្ហាញផ្លូវការជូនអង្គប្រជុំ
- សុំឲ្យទីប្រឹក្សាបច្ចេកទេសធ្វើបទបង្ហាញជូនអង្គប្រជុំរួមដែលមានការចូលរួម ពីសំណាក់ភាគីពាក់ព័ន្ធ ដើម្បីប្រឹក្សាផ្តល់យោបល់ចុងក្រោយ មុននឹងដាក់របាយការណ៍ផ្លូវការជូនCCC/GFATM នៅខែធ្នូ ឆ្នាំ២០១៥។ ព្រោះថាឯកសារនេះ មានសារៈសំខាន់ជាគន្លឹះសម្រាប់ CCC/GFATM ក៏ដូចជារាជរដ្ឋាភិបាលប្រើប្រាស់ជាមូលដ្ឋាន នៃការសម្រេចចិត្តលើការគ្រប់គ្រងធនធានមនុស្សដែលបន្តអនុវត្តគម្រោងមូលនិធិសកលចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។

កិច្ចពិភាក្សាបានបញ្ចប់នៅវេលាម៉ោង១៦:៣០ ប្រកបដោយភាពស្និទស្នាលនិងការយោគយល់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០១៥

បានឃើញ និង ឯកភាព
ទេសរដ្ឋមន្ត្រី ប្រធានអ.ជ.ប.ជ.អ

អ្នកធ្វើរបាយការណ៍

ឌុសថ. ឈឹម ឃិនជាអ៊ត

អៀង មូលី